ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ : ២៩១.អនក្រ.បក

# អនុក្រឹត្យ

## ស្តីពី

## ការបង្កើតគណៈបញ្ជាការសន្តិសុខអចិន្ត្រៃយ៍ សម្រាប់ការបោះឆ្នោតថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ (គ.ស.អ)

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨២៣/១៩៨១ ចុះថ្ងៃទី ២២ ខែសីហា ឆ្នាំ២០២៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី ២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦០៥/០២០ ចុះថ្ងៃទី ២០ ខែមិថុនា ឆ្នាំ២០០៥ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៣១៥/០០៣ ចុះថ្ងៃទី២៦ ខែមីនា ឆ្នាំ២០១៥ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៨ ចុះថ្ងៃទី ២៤ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សារាជធានី ក្រុមប្រឹក្សាខេត្ត ក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សាស្រុក ក្រុមប្រឹក្សាខណ្ឌ
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២១៥/០១៥ ចុះថ្ងៃទី ១១ ខែធ្នូ ឆ្នាំ២០១៥ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់
- យោងតាមការចាំបាច់របស់រាជរដ្ឋាភិបាល

## សម្រេច

**មាត្រា ១.-**

ត្រូវបានបង្កើត **គណៈបញ្ជាការសន្តិសុខអចិន្ត្រៃយ៍សម្រាប់ការបោះឆ្នោតថ្នាក់ជាតិ ថ្នាក់ក្រោមជាតិ** ហៅកាត់ថា «**គ.ស.អ**» ដើម្បីបញ្ជាដឹកនាំកិច្ចការការពារការពិនិត្យបញ្ជីឈ្មោះ និង

ការចុះឈ្មោះបោះឆ្នោតប្រចាំឆ្នាំ និងការបោះឆ្នោតថ្នាក់ជាតិ ថ្នាក់ក្រោមជាតិ គ្រប់នីតិកាល ដែលសមាសភាពមានដូចខាងក្រោម ៖

| | |
|---|---|
| ១. ឯកឧត្តម អភិសន្តិបណ្ឌិត **ស សុខា** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ | ជាប្រធាន |
| ២. ឯកឧត្តម នាយឧត្តមសេនីយ៍ **ទៀ សីហា** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការពារជាតិ | អនុប្រធាន |
| ៣. ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ **អូន ព័ន្ធមុនីរ័ត្ន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ | អនុប្រធាន |
| ៤. ឯកឧត្តម **សុខ ចិន្ដាសោភា** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ | អនុប្រធាន |
| ៥. ឯកឧត្តម **កើត រិទ្ធ** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ | អនុប្រធាន |
| ៦. រដ្ឋមន្ត្រីក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា | សមាជិក |
| ៧. រដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ | សមាជិក |
| ៨. រដ្ឋមន្ត្រីក្រសួងព័ត៌មាន | សមាជិក |
| ៩. រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម | សមាជិក |
| ១០. ប្រធានអង្គភាពព័ត៌មាន និងប្រតិកម្មរហ័ស នៃទីស្ដីការគណៈរដ្ឋមន្ត្រី | សមាជិក |
| ១១. អគ្គលេខាធិការក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា | សមាជិក |
| ១២. រដ្ឋលេខាធិការ ក្រសួងការពារជាតិ | សមាជិក |
| ១៣. រដ្ឋលេខាធិការប្រចាំការ ក្រសួងមហាផ្ទៃ | សមាជិក |
| ១៤. រដ្ឋលេខាធិការទទួលការងារផ្នែកសន្តិសុខ នៃក្រសួងមហាផ្ទៃ | សមាជិក |
| ១៥. រដ្ឋលេខាធិការទទួលការងារអត្តសញ្ញាណកម្ម នៃក្រសួងមហាផ្ទៃ | សមាជិក |
| ១៦. រដ្ឋលេខាធិការទទួលការងារបច្ចេកវិទ្យាឌីជីថល និងផ្សព្វផ្សាយអប់រំ នៃក្រសួងមហាផ្ទៃ | សមាជិក |
| ១៧. រដ្ឋលេខាធិការទទួលការងារអន្តោប្រវេសន៍ នៃក្រសួងមហាផ្ទៃ | សមាជិក |
| ១៨. រដ្ឋលេខាធិការទទួលការងារផ្នែកសណ្តាប់ធ្នាប់សាធារណៈ និងចរាចរណ៍ នៃក្រសួងមហាផ្ទៃ | សមាជិក |
| ១៩. រដ្ឋលេខាធិការទទួលការងារកិច្ចការរដ្ឋបាលរាជធានី ខេត្ត ខណ្ឌ នៃក្រសួងមហាផ្ទៃ | សមាជិក |
| ២០. អគ្គស្នងការនគរបាលជាតិ | សមាជិកអចិន្ត្រៃយ៍ |
| ២១. អគ្គមេបញ្ជាការកងយោធពលខេមរភូមិន្ទ | សមាជិក |
| ២២. អគ្គលេខាធិការ នៃអគ្គលេខាធិការដ្ឋាន ក្រសួងមហាផ្ទៃ | សមាជិក |
| ២៣. អគ្គនាយក នៃអគ្គនាយកដ្ឋានអត្តសញ្ញាណកម្ម ក្រសួងមហាផ្ទៃ | សមាជិក |

២៤. អគ្គនាយក នៃអគ្គនាយកដ្ឋានអន្តោប្រវេសន៍ ក្រសួងមហាផ្ទៃ សមាជិក
២៥. អគ្គនាយក នៃអគ្គនាយកដ្ឋានភស្តុភារ និងហិរញ្ញវត្ថុ ក្រសួងមហាផ្ទៃ សមាជិក
២៦. អគ្គមេបញ្ជាការរង ខ.ភ.ម និងមេបញ្ជាការកងរាជអាវុធហត្ថលើផ្ទៃប្រទេស សមាជិក
២៧. អគ្គមេបញ្ជាការរង ខ.ភ.ម និងជាមេបញ្ជាការកងទ័ពជើងគោក សមាជិក
២៨. អគ្គមេបញ្ជាការរង ខ.ភ.ម និងជាមេបញ្ជាការកងទ័ពជើងទឹក សមាជិក
២៩. អគ្គមេបញ្ជាការរង ខ.ភ.ម និងជាមេបញ្ជាការកងទ័ពជើងអាកាស សមាជិក
៣០. អភិបាល នៃគណៈអភិបាលរាជធានី ខេត្ត និងជាប្រធានគណៈបញ្ជាការឯកភាពរដ្ឋបាលរាជធានី ខេត្ត សមាជិក

**មាត្រា ២._**

តួនាទី ភារកិច្ចរបស់ **គ.ស.អ** រួមមាន ៖

- ដឹកនាំបញ្ជា តាមដាន ត្រួតពិនិត្យ រៀបចំ គ្រប់គ្រង និងប្រើប្រាស់កម្លាំងមានសមត្ថកិច្ចពាក់ព័ន្ធ ដើម្បីធានាឲ្យដំណើរការការពិនិត្យបញ្ជីឈ្មោះ និងចុះឈ្មោះបោះឆ្នោតប្រចាំឆ្នាំ និងការបោះឆ្នោតថ្នាក់ជាតិ ថ្នាក់ក្រោមជាតិ តាមនីតិកាល និងអាណត្តិនីមួយៗ ប្រព្រឹត្តទៅប្រកបដោយសន្តិសុខ មានសណ្តាប់ធ្នាប់របៀបរៀបរយ និងមានសុវត្ថិភាព គ្មានការភ័យខ្លាច គ្មានការបំភិតបំភ័យ គ្មានការគំរាមកំហែង និងគ្មានអំពើហិង្សាផ្សេងៗ

- សហការជាមួយ **គ.ជ.ប** ដើម្បីកសាងផែនការអន្តរស្ថាប័នបម្រើឲ្យកិច្ចការពារគ្រប់យុទ្ធនាការពិនិត្យបញ្ជីឈ្មោះ និងចុះឈ្មោះបោះឆ្នោតប្រចាំឆ្នាំ និងការបោះឆ្នោតថ្នាក់ជាតិ ថ្នាក់ក្រោមជាតិ តាមនីតិកាល និងអាណត្តិនីមួយៗ

- ធ្វើការពិគ្រោះយោបល់ និងចាត់ចែងផ្តល់កិច្ចសហប្រតិបត្តិការផ្នែកសន្តិសុខ សណ្តាប់ធ្នាប់សាធារណៈ និងសុវត្ថិភាពសង្គម រួមទាំងវិស័យការងារផ្សេងៗទៀត តាមសំណើរបស់ **គ.ជ.ប** ឬ/និង **គណៈកម្មការរៀបចំការបោះឆ្នោតគ្រប់លំដាប់ថ្នាក់** ស្របតាមច្បាប់ លិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធ ពិសេសច្បាប់ស្តីពីការបោះឆ្នោត បទបញ្ជា នីតិវិធី ក្រមសីលធម៌ និងសេចក្តីណែនាំពាក់ព័ន្ធរបស់ **គ.ជ.ប**

- ផ្សព្វផ្សាយគោលការណ៍សកម្មភាព និងលទ្ធផលនៃការអនុវត្តតួនាទី ភារកិច្ចរបស់ **គ.ស.អ** ក៏ដូចជា ខ្លឹមសារនានាពាក់ព័ន្ធដល់ការធានាសន្តិសុខសម្រាប់ដំណើរការពិនិត្យបញ្ជីឈ្មោះ និងចុះឈ្មោះបោះឆ្នោតប្រចាំឆ្នាំ និងការបោះឆ្នោតថ្នាក់ជាតិ ថ្នាក់ក្រោមជាតិ តាមនីតិកាល និងអាណត្តិនីមួយៗ ជូនដល់សាធារណមតិជាតិ អន្តរជាតិ ឲ្យបានយល់ដឹង និងជ្រួតជ្រាប

- ប្រមែប្រមូលព័ត៌មានអំពីហេតុការណ៍ ឬព្រឹត្តិការណ៍នានាពាក់ព័ន្ធដល់សភាពការណ៍សន្តិសុខនៃកិច្ចដំណើរការបោះឆ្នោត និងព័ត៌មានពីគ្រប់ប្រភព ដែលបានផ្សព្វផ្សាយធ្វើឲ្យមានផលប៉ះពាល់ដល់បរិយាកាសសន្តិសុខនៃកិច្ចដំណើរការបោះឆ្នោត ដើម្បីធ្វើការបកស្រាយ បំភ្លឺ ប្រតិកម្មវាយបកបន្សាបឥទ្ធិពល បញ្ចៀសការភាន់ច្រលំពីសំណាក់សាធារណមតិជាតិ អន្តរជាតិ។ ក្នុងករណីធ្ងន់ធ្ងរ ត្រូវសហការជាមួយអាជ្ញាធរមានសមត្ថកិច្ច ដើម្បីអនុវត្តវិធានការច្បាប់

- ចាត់ចែងគ្រប់គ្រង និងប្រើប្រាស់ធនធានមនុស្ស សម្ភារ ឧបករណ៍បច្ចេកទេស និងមធ្យោបាយគ្រប់ប្រភេទរបស់ក្រសួង/ស្ថាប័ន និងអង្គភាពពាក់ព័ន្ធដែលមានស្រាប់ ក្នុងទិសដៅជំរុញយុទ្ធនាការការពារការពិនិត្យបញ្ជីឈ្មោះ និងចុះឈ្មោះបោះឆ្នោតប្រចាំឆ្នាំ ការបោះឆ្នោតថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ឲ្យទទួលបានជោគជ័យ

- ធ្វើការបណ្តុះបណ្តាល និងអប់រំផ្សព្វផ្សាយគោលការណ៍ច្បាប់ និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធនានាសំដៅលើកកម្ពស់សមត្ថភាពជូនដល់មន្ត្រីប្រតិបត្តិ គ្រប់យន្តការ រចនាសម្ព័ន្ធសន្តិសុខបោះឆ្នោត និងភ្នាក់ងារសន្តិសុខបោះឆ្នោត ឲ្យបានជ្រួតជ្រាប ដើម្បីសហការអនុវត្តជានាសន្តិសុខសណ្តាប់ធ្នាប់សាធារណៈ និងសុវត្ថិភាពសម្រាប់ការបោះឆ្នោតឲ្យមានលក្ខណៈកាន់តែប្រសើរឡើង និងប្រកបដោយការទទួលខុសត្រូវខ្ពស់

- លើកគម្រោងស្នើថវិកាបំប៉នដល់គ្រប់យន្តការ រចនាសម្ព័ន្ធ និងភ្នាក់ងារសន្តិសុខបោះឆ្នោត និងគម្រោងថវិកាសម្រាប់ការផ្គត់ផ្គង់ជាសម្ភារ មធ្យោបាយ ប្រេងឥន្ធនៈ ការបណ្តុះបណ្តាល និងការចំណាយចាំបាច់ផ្សេងៗទៀត បម្រើដល់កិច្ចប្រតិបត្តិការការពារយុទ្ធនាការចុះឈ្មោះបោះឆ្នោត ការបោះឆ្នោតថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ដើម្បីដាក់ជូនរាជរដ្ឋាភិបាល ពិនិត្យ និងអនុម័ត។

**មាត្រា ៣._**

**គ.ស.អ** មានសិទ្ធិប្រើប្រាស់ត្រារបស់ទីស្តីការគណៈរដ្ឋមន្ត្រី ក្នុងការបំពេញមុខងារ និងភារកិច្ចរបស់ខ្លួន ហើយមានលេខាធិការដ្ឋានមួយជាសេនាធិការ នៅអគ្គស្នងការដ្ឋាននគរបាលជាតិ ដែលសមាសភាព និងតួនាទី ភារកិច្ចរបស់លេខាធិការដ្ឋាន នឹងត្រូវកំណត់តាមសេចក្តីសម្រេចរបស់ប្រធាន **គ.ស.អ**។

អនុប្រធាន និងសមាជិករបស់ **គ.ស.អ** ត្រូវចូលរួមគ្រប់កិច្ចប្រជុំ តាមការអញ្ជើញរបស់ប្រធាន **គ.ស.អ**។

**មាត្រា ៤._**

គណៈអភិបាលរាជធានី ខេត្ត និងជាគណៈបញ្ជាការឯកភាពរដ្ឋបាលរាជធានី ខេត្ត ដែលមានស្រាប់ ត្រូវបានកំណត់ជាស្វ័យប្រវត្តិ ជាយន្តការ និងរចនាសម្ព័ន្ធសន្តិសុខបោះឆ្នោតថ្នាក់ក្រោមជាតិ ដើម្បីគ្រប់គ្រងដឹកនាំបញ្ជា និងត្រួតពិនិត្យលើការអនុវត្តរបស់ភ្នាក់ងារសន្តិសុខបោះឆ្នោត ក្នុងដែនសមត្ថកិច្ចរាជធានី ខេត្តរៀងៗខ្លួន។ កម្លាំងនគរបាល ឬ/និងកងរាជអាវុធហត្ថ ឬ/និងកងយោធពលខេមរភូមិន្ទ ព្រមទាំងប្រជាការពារ ដែលមានមូលដ្ឋានឈរជើងក្នុងភូមិសាស្ត្ររាជធានី ខេត្តនីមួយៗ ត្រូវបានរៀបចំឲ្យបំពេញភារកិច្ចជា**ភ្នាក់ងារសន្តិសុខបោះឆ្នោត** ផ្អែកតាមការកំណត់ក្នុងផែនការអន្តរស្ថាប័ន។

**មាត្រា ៥._**

បទប្បញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយពីអនុក្រឹត្យនេះ ត្រូវចាត់ទុកជានិរាករណ៍។

**មាត្រា ៦._**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងការពារជាតិ រដ្ឋមន្ត្រីក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ រដ្ឋមន្ត្រី-ប្រធានស្ថាប័នពាក់ព័ន្ធ អភិបាល នៃគណៈអភិបាលរាជធានី ខេត្ត និងសមាសភាពដូចមានចែងក្នុងមាត្រា១ នៃអនុក្រឹត្យនេះ ត្រូវទទួលបន្ទុកអនុវត្តភារកិច្ចតាមសមត្ថកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃ ពុធ ៦កើត ខែ ភទ្របទ ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ២០ ខែ កញ្ញា ឆ្នាំ ២០២៣

**នាយករដ្ឋមន្ត្រី**

**សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត**

**កន្លែងទទួល ៖**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត
- ខុទ្ទកាល័យសម្តេចមហាបវរធិបតីនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា ១ និងមាត្រា ៦
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ